ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦

**សេចក្តីថ្លែងការណ៍**
**របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤**

នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដូចខាងក្រោម៖

- អំពើប្រល័យពូជសាសន៍លើជនជាតិចាម
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញមកលើ“ប្រជាជន ១៧ មេសា” អតីតទាហានលន់ នល់ កម្មាភិបាលភូមិភាគកណ្តាល (ឧត្តរចាស់) គ្រួសាររបស់ពួកគេ អ្នកក្រោមបង្គាប់របស់ពួកគេ ប្រជាជនមកពីភូមិភាគបូព៌ា “សមាសភាពមិនល្អ” និង“ខ្មាំងផ្ទៃក្នុង” ការធ្វើទុក្ខបុកម្នេញមកលើប្រជាជនចាម និងប្រជាជនវៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត រួមមាន អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភលើផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ ការធ្វើបាបរាងកាយ ពលកម្មដោយបង្ខំ និងការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌
- ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ រួមមាន មនុស្សឃាតដោយចេតនា។

ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានចោទថាបានប្រព្រឹត្តឡើងនៅការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ ទីកន្លែងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខមិត្តសុប(គរ) មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សទួលបេង និងវត្តអង្គញដី មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ ទីកន្លែងសម្លាប់មនុស្សភ្នំប្រុស មន្ទីរសន្តិសុខវត្តតាមះ មន្ទីរសន្តិសុខចម្ការស្វាយចន្ទី មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក មន្ទីរសន្តិសុខវត្តស្រង៉ែ និងទីតាំងផ្សេងៗនៅក្នុងខេត្តកំពង់ចាម។

បទចោទប្រកាន់ដែលបានប្រកាសនៅថ្ងៃនេះ រាប់បញ្ចូលទាំងបទចោទប្រកាន់ថ្មី ទាំងបទចោទប្រកាន់ពីមុនដែលបានធ្វើឡើងរួចហើយនៅពេលដែល អោ អាន ចូលបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។ ចាប់តាំង

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ
www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555
www.eccc.gov.kh

ពីការ បង្ហាញខ្លួនលើកដំបូងមក អោ អាន តាមរយៈសហមេធាវីរបស់គាត់ ត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរសព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរសព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh